**មាត្រា ៥ :** អនុក្រឹត្យនេះ មានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ១២ អនក្រ
# ស្តីពីការប្តូរឈ្មោះស្រុក ធីរូមខេត្ត
# សង្កាត់ ក្នុងខេត្ត រតនគិរី

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះស្រុក បានលុង មកជាស្រុក អូរជុំ ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះធីរូមខេត្ត របស់ខេត្តរតនគិរី មកជាស្រុក បានលុង ដែលមានទីតាំងរដ្ឋបាលសាលាស្រុក នៅភូមិទី ៣ ឃុំ ឡាបានសៀក ។

**មាត្រា ៣ :** ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួនបីចំណុះធីរូមខេត្តមកជាឃុំចំនួនបីចំណុះស្រុក បានលុងគឺ :

- សង្កាត់ យក្សឡោម មកជា ឃុំ យក្សឡោម
- សង្កាត់ ឡាបានសៀក មកជា ឃុំ ឡាបានសៀក
- សង្កាត់ កេសុី មកជា ឃុំ កាចាញ ។

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិកការដ្ឋាន និងអភិបាលខេត្ត រតនគីរី ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀង១ខ្លួន ។

**មាត្រា ៦ :** អនុក្រឹត្យនេះមានអានុភាពអនុវត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ១៣ អនក្រ
## ស្តីពីការប្តូរធីរូមខេត្តជាស្រុក និង ឈ្មោះសង្កាត់
## ក្នុងខេត្តស្ទឹងត្រែង

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ :** ត្រូវបានប្តូរធីរូមខេត្តរបស់ខេត្តស្ទឹងត្រែង មកជាស្រុកស្ទឹងត្រែង ដែលមានទីតាំងរដ្ឋបាលសាលាស្រុកនៅ ភូមិ កណ្តាល ឃុំស្ទឹងត្រែង ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួន ០៤ ចំណុះធីរូមខេត្ត មកជាឃុំចំនួន ០៤ ចំណុះស្រុកស្ទឹងត្រែងគឺ ÷

សង្កាត់ ១ មកជា ឃុំ ស្ទឹងត្រែង

សង្កាត់ ២ មកជា ឃុំ ស្រះឫស្សី

www.pheakdeylaw.com